ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ០៤២.១៣៩៩៩/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៣

**គោរពជូន**
**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**__កម្មវត្ថុ:__** សំណើសុំអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៨ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នឹងរៀបចំកិច្ចប្រជុំលើកទី៨ របស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តលើឯកសារសំខាន់ៗដែលមានចែងនៅក្នុងរបៀបវារៈ និងកម្មវិធីដូចជូនភ្ជាប់មកជាមួយ ។

កិច្ចប្រជុំនេះ នឹងរៀបចំធ្វើនៅថ្ងៃទី**៣០ ខែឧសភា ឆ្នាំ២០១៣** វេលាម៉ោង០៨ :00 នាទីព្រឹក នៅសាលប្រជុំរបស់ក្រសួងមហាផ្ទៃ (អគារ S) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ។

អាស្រ័យហេតុនេះ ខ្ញុំសូមអញ្ជើញឯកឧត្តមចូលរួមកិច្ចប្រជុំខាងលើ និងជូនដំណឹងដល់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ព្រមទាំងប្រធានក្រុមប្រឹក្សា និងអភិបាល ក្រុង ស្រុក ដូចមានបញ្ជាក់នៅក្នុងបញ្ជីរាយនាមអ្នកចូលរួម ក្នុងកិច្ចប្រជុំនេះ តាមការគួរ ។

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងទទួលរ៉ាប់រងចំពោះថ្លៃធ្វើដំណើរ និងប្រាក់ឧបត្ថម្ភបេសកកម្មចំពោះអ្នកចូលរួមទាំងអស់ និងចំពោះមន្ត្រីបើកបររបស់គម្រោងផអពា តែប៉ុណ្ណោះ ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់ សេដ្ឋា

*លេខទូរស័ព្ទទំនាក់ទំនង*
*០១២ ៤៥៧ ៩៩២*